4

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ: ១២១ "ក្រ១០ឃ"

-ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨

-សំណុំរឿងព្រហ្មទណ្ឌលេខ ២២៣២

ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧

-សំណុំរឿងស៊ើបសួរលេខ ១៣៨៦

ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧

-សំណុំរឿងជំនុំជម្រះលេខ ៣៦៣០

ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០១៨ វេលាម៉ោង ១៤ និង ០០ នាទីរសៀល នៅសាលសវនាការទី៤ ដោយមានសមាសភាព ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោកចៅក្រម [redacted] ាប្រធានក្រុមប្រឹក្សា

-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

-លោកចៅក្រម [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២២៣២ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ហ៊ីង ( [redacted] លីហ៊ីង ) ហៅ ហ៊ីង ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករសំណង់ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកំពង់ឆ្នាំ ឪពុកឈ្មោះ [redacted] ហុង (រ) ម្តាយឈ្មោះ [redacted] សារី (រ) នៅលីវ ទោសពីមុនគ្មាន ជាតិជន។ (គេចខ្លួន)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣៦០ (៩១) ដ.ច.ន ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ជាប់ចោទពីបទ ឃាតកម្ម ប្រព្រឹត្តនៅភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

២-ឈ្មោះ [redacted] យ៉ត ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែង កំណើតភូ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នផ្ទះជួល ភូមិកាកាប សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] យោន "រ" ម្តាយឈ្មោះ [redacted] បាន "រ" ប្រពន្ធឈ្មោះ [redacted] ស្រីយុត មានកូន០៣ នាក់ ទោសពីមុនគ្មាន ជាតិជន។ (ក្នុងឃុំ)

-ឃាត់ខ្លួនថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧, ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៥៩៥ (៩១)ដ.ឃ.ង ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។



Scanned with CamScanner

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

៣-ឈ្មោះ [redacted] តុ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែង កំណើតភូ [redacted] ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះជួល ភូមិតាំងក្រសាំង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឈ្មួន "ស" ម្ដាយឈ្មោះ [redacted] សាម៉ឿន "រ" នៅលីវ ទោសពីមុនគ្មាន ជាទីតិជន។ (ក្នុងឃុំ)

-ឃាត់ខ្លួនថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧, ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៥៩៦ (៩១)ង.ឃ.ង ចុះថ្ងៃទី 04 ខែមេសា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ជាប់ចោទពីបទ **សមគំនិតក្នុងអំពើឃាតកម្ម** ប្រព្រឹត្តនៅភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ១៩៩ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] នូ ភេទស្រី អាយុ២៤ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីយប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ នៅចំណុចក្នុងរោងកម្មករ នៃការដ្ឋានសំណង់ផ្ទះល្វែង ភូមិចំការ ឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានករណីឃាតកម្ម កើតឡើងខណៈជនជាប់ចោទមួយក្រុម មានគ្នា ០៣ ទៅ ០៤ នាក់ ក្នុង នោះមានឈ្មោះ [redacted] ហ៊ីង, ឈ្មោះ [redacted] យ៉ត, ឈ្មោះ [redacted] តុ និងបក្ខពួកកំពុងផឹកស៊ីនៅការដ្ឋានសំណង់កើតហេតុខាងលើ ក៏បានឃើញជនរងគ្រោះឈ្មោះ [redacted] ស៊ីវុធថារិន ភ្លាមនោះឈ្មោះ [redacted] ហ៊ីង ក៏បានយកបំពង់ទីបមូលប្រវែង 0,៩៩ ម៉ែត្រ វាយទៅលើជនរង គ្រោះចំនួន៣ទៅ៤ ទីប បណ្ដាលឱ្យជនរងគ្រោះស្លាប់ នៅនឹងកន្លែងកើតហេតុ ហើយជនជាប់ចោទបាននាំគ្នារត់គេចអស់។ បន្ទាប់មកសមត្ថកិច្ចធ្វើការស្វែងរកចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] តុ និងឈ្មោះ [redacted] យ៉ត រីឯជនដៃដល់ឈ្មោះ [redacted] ហ៊ីង ភេទប្រុស។

-បានឃើញ របាយការណ៍សំយោគលេខ ១៩៩/០១៧ រ.ប.ក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៤៥១ អ.យ.វ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣៦០(៩១)ង.ច.ខ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៩៧៦ អ.យ.វ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចលើកលែងចោទប្រកាន់លេខ ៤១០៦ "៩១" ង.ង ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤១០៦ "៩១" ង.ង ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។



Scanned with CamScanner

-បានឃើញ ដីកាបង្គាប់ឱ្យរក្សានៅក្នុងឃុំបណ្ដោះអាសន្នលេខ ៧៦៩៣ "ខ១" ជ.ឃ.ជ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបង្គាប់ឱ្យរក្សានៅក្នុងឃុំបណ្ដោះអាសន្នលេខ ៧៦៩២ "ខ១" ជ.ឃ.ជ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted]ហ៊ីង ([redacted]លីហ៊ីង) ហៅ ហ៊ីង (គេចខ្លួន)។

-ជនជាប់ចោទឈ្មោះ [redacted] យ៉ត បានឆ្លើយថា: កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង៥ និង០០នាទីល្ងាច ពួកខ្លួនមានគ្នាប្រហែល០៨នាក់ រួបខ្លួន, ឈ្មោះ តុ ,ឈ្មោះ ហ៊ីង ,ឈ្មោះ [redacted] ទី, ឈ្មោះ ខ្នា និងបីនាក់ទៀតពុំស្គាល់ឈ្មោះ ពួកខ្លួនអង្គុយផឹកដល់ម៉ោងប្រហែល ០៦ ល្ងាច ផឹកស្រាអស់៣លីត្រ ពេលកំពុងផឹកពួកខ្លួនមិនបានឈ្លោះគ្នា។ ដល់ម៉ោង ៧និង០០នាទី ខ្លួនក៏បានជិះម៉ូតូទៅកន្លែងធ្វើការ និងបានអង្គុយលេងជាមួយប្រពន្ធឈ្មោះ ហ៊ីង ស្រាប់តែជនរងគ្រោះបានដើរមកសួររកឈ្មោះ តុ ពេលនោះឈ្មោះ ហ៊ីង បានឆ្លើយថា ឈ្មោះ តុ នៅក្នុងមុង រួចជនរងគ្រោះក៏ដើរទៅដាស់ឈ្មោះ តុ តែឈ្មោះ តុ មិនងើប រួចក៏ដើរមកវិញ តែមិនដឹងថា ជនរងគ្រោះនិយាយអ្វីជាមួយឈ្មោះ ហ៊ីង នោះទេ ព្រោះរវល់តែនិយាយជាមួយប្រពន្ធរបស់ឈ្មោះហ៊ីង ស្រាប់តែពេលនោះខ្លួនលឺសូរសំលេងផុសៗ ក្រឡេកមើលទៅឃើញជនរងគ្រោះដួល ហើយឈ្មោះ ហ៊ីង បោះបំពង់ទីបចោល ខ្លួនក៏បានរត់ចេញមកក្រៅ រួចឈ្មោះ តុ ក៏រត់ចេញពីក្នុងមុងនិយាយជាមួយឈ្មោះ ហ៊ីង តែខ្លួនមិនដឹងនិយាយពីអ្វីនោះទេ ពេលនោះឈ្មោះ តុ បានរត់ទៅផ្ទះមេការសំណង់ខ្លួនក៏ជិះម៉ូតូទៅផ្ទះវិញ។ ខ្លួនមិនដែលមានទំនាស់អ្វីជាមួយជនរងគ្រោះនោះទេ ព្រោះខ្លួនទើបតែមកធ្វើការនៅការដ្ឋាននេះបាន៥ថ្ងៃប៉ុណ្ណោះ។

-ជនជាប់ចោទឈ្មោះ [redacted] តុ បានឆ្លើយថា: កាលពីថ្ងៃទី ខែមិនចាំ ឆ្នាំ២០១៧ វេលាម៉ោង៥ និង០០នាទី ពួកខ្លួនមានគ្នាប្រហែល៨នាក់ មានរូបខ្លួន ,ឈ្មោះ ហ៊ីង ឈ្មោះ យ៉ត និងប្រាំនាក់ទៀតមិនស្គាល់ឈ្មោះ ពួកខ្លួនអង្គុយផឹកដល់ម៉ោង៦ល្ងាច អស់ស្រា៣លីត្រ ហើយក៏មិនបានឈ្លោះប្រកែកគ្នាដែរ រួចក៏បែកគ្នាទៅផ្ទះរៀងៗខ្លួន ចំណែកខ្លួនស្រវឹងពេកក៏ដេកលក់ក្នុងមុងនៅការដ្ឋានសំណង់ ដោយមិនដឹងថា នរណាមកកេះខ្លួនទេ ពេលដឹងខ្លួនឡើងទើបឃើញមនុស្សដេកស្លាប់នៅក្បែរមុខរោងខ្លួនដេក ពេលនោះឈ្មោះ ហ៊ីង និងទីនោះដែរ រួចឈ្មោះ ហ៊ីង បានបបួលខ្លួនរត់ តែខ្លួនពុំរត់ទៅជាមួយទេ ព្រោះខ្លួនពុំបាន ប្រព្រឹត្តពេលនោះឈ្មោះ ហ៊ីង ក៏បានរត់គេចបាត់តែម្តង។ ខ្លួនពុំបានសមគំនិត និងចូលរួមវាយសម្លាប់ទៅលើជនរងគ្រោះនោះទេ។ នៅថ្ងៃកើតហេតុនោះ ខ្លួនបានលឺសម្លេងឈ្លោះប្រកែកគ្នារវាងឈ្មោះហ៊ីង , ឈ្មោះ យ៉ត និងជនរងគ្រោះអំពីរឿងស្រា ស្រាប់តែលឺសម្លេងផុសៗ ខ្លួនក៏ក្រោកមកឃើញជនរងគ្រោះដួលនៅ កន្លែងកើតហេតុ និងបានឃើញឈ្មោះ ហ៊ីង កាន់ដំបងទីបនឹងដៃ ចំណែកឈ្មោះ យ៉ត ក៏នៅទីនោះដែរ តែមិនឃើញមានកាន់អ្វីនោះទេ ខ្លួនក៏បានទូរស័ព្ទទៅប្រាប់ឈ្មោះ [redacted] ផុល ដែលជាមេការរបស់ការដ្ឋានថា មានគេវ៉ៃគ្នាបណ្តាលឱ្យជនរងគ្រោះស្លាប់ដោយឈ្មោះ [redacted] លីហ៊ីង និងឈ្មោះ[redacted]យ៉ត ជាអ្នកវាយ។ ខ្លួនបានរាយការណ៍ប្រាប់មេការរួចហើយ តែមិនបានប្តឹងសមត្ថកិច្ចនោះទេ ព្រោះខ្លួនទើបតែមកធ្វើការ ណាមួយមិនស្គាល់ផង ពេលសមត្ថកិច្ចឃាត់ខ្លួន ខ្លួនបានឆ្លើយប្រាប់ពីហេតុការណ៍ទាំងនោះអស់ហើយ ខ្លួនមិនដែលមានទំនាស់អ្វីជាមួយជនរងគ្រោះនោះទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នូ បានឆ្លើយថា: ខ្លួនត្រូវជាប្រពន្ធរបស់ជនរងគ្រោះឈ្មោះ [redacted] ស៊ីវុធថារិន។ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ៦ និង០០ នាទីយប់ ខ្លួននិងប្តីបានទៅផ្ទះម្តាយ ហូបបាយជុំគ្នាដល់ម៉ោង៩យប់ ទើបត្រឡប់មកផ្ទះជួលវិញ ហើយគាត់បានដើរទៅការដ្ឋានសំណង់ដើម្បីសុំបារីគេជក់ រហូតដល់ម៉ោង



Scanned with CamScanner

១២យប់ មិនឃើញគាត់ត្រឡប់មកផ្ទះវិញ ខ្លួនក៏បានដើរទៅរកគាត់តែមិនឃើញ។ លុះមកដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ វេលាម៉ោង៦និង៣០នាទីព្រឹក ស្រាប់តែឃើញប្តីខ្លួនដេកស្លាប់នៅដីវាល។ ប្តីខ្លួនមិនដែលមានជំលោះ ជាមួយអ្នកណានោះទេ ហើយនៅថ្ងៃកើតហេតុខ្លួនមិនដឹងថាអ្នកណាវាយប្តីរបស់ខ្លួននោះទេ។ ខ្លួនស្គាល់តែឈ្មោះ [redacted] តុ ប៉ុណ្ណោះ មិនស្គាល់ឈ្មោះ [redacted] លីហឹង នោះទេ ហើយប្តីខ្លួនក៏មិនដែលមានទំនាស់ជាមួយឈ្មោះ [redacted] តុ នោះដែរ។ ពេលនេះខ្លួនឈប់ប្តឹងឈ្មោះ [redacted] តុ ហើយក៏មិនប្តឹងទាមទារសំណងអ្វីទៀតដែរ ប៉ុន្តែខ្លួនទូរប្តឹងទាមទារសំណង់ពីឈ្មោះ [redacted] យ៉ត និងឈ្មោះ [redacted] លីហ៊ឹង ក្នុងម្នាក់ៗចំនួន ៥០០០ (ប្រាំពាន់) ដុល្លារអាមេរិក។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ [redacted] ធុល ថា: កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង១៧ និង០០នាទី ខ្លួនដេកនៅកន្លែងរោងស្នាក់នៅ រហូតដល់ម៉ោង ១០យប់ ស្រាប់តែឈ្មោះ ធី (យ៉ត) ជាមេការខាងសំណង់បានទូរស័ព្ទមកខ្លួនឲ្យទៅមើលរោងកម្មករស្នាក់នៅរបស់គាត់ព្រោះមានអ្នកវាយគ្នា។ ពេលនោះខ្លួន និងឈ្មោះ ជា បាននាំគ្នាទៅ ហើយបានឃើញឈ្មោះ តុ អង្គុយនៅក្នុងផ្ទះឈ្មោះ ធី រួចខ្លួនសួរឈ្មោះ តុ ថា មានរឿងអីបានជាឈ្មោះ ធី ទូរស័ព្ទហៅខ្លួនឲ្យមកឈ្មោះ តុ ប្រាប់ថា ឈ្មោះ ហ៊ុង និងប្រពន្ធរួមទាំងឈ្មោះ ធី ហៅយ៉ត បាននាំគ្នាវាយឈ្មោះ [redacted] ស៊ីវុធថាវិន ហៅស្នា ដេកស្តូកស្តឹងនៅមុខរោងកម្មករ មិនដឹងស្លាប់ រឺរស់នោះទេ។ បន្ទាប់មកខ្លួន, ឈ្មោះ តុ និងឈ្មោះ ជា បាននាំគ្នាដើរទៅមើល ឃើញឈ្មោះ ស្នា ដេកផ្អៀង មានឈាមហូរចេញពីក្បាល ខ្លួន និងឈ្មោះ តុ បានចាប់ជើងទាញ មើលទើបដឹងថាស្លាប់ ចំណែកឈ្មោះ ជា ឈរមើល រីឯប្រពន្ធរបស់ឈ្មោះ ធី (ឈ្មោះ ចាន់) ប្រាប់ឲ្យជួយសែងសាកសព ចេញពីមុខរោងកម្មករកុំឲ្យអ្នកដេកខ្លាច ខ្លួននិងឈ្មោះ តុ ក៏បានយកភួយក្រណាត់ដាក់សព និងសែងយកទៅទុក នៅចំងាយពីរោងប្រហែល១០ម៉ែត្រ រួចក៏នាំគ្នាទៅដេក។ លុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ ម៉ោង១០ព្រឹក សមត្ថកិច្ចបានហៅខ្លួនមកសាកសួរតែម្តង ខ្លួនមិនបានដឹងរឿងហេតុវាយគ្នានោះទេ ឈ្មោះ ហ៊ឹង ជាកម្មករសំណង់ ចំណែកជនរងគ្រោះឈ្មោះ ស្នា ជាអ្នករកត្រី ស្នាក់នៅបណ្តោះអាសន្នក្បែរការដ្ឋានសំណង់។

## សេចក្តីសន្និដ្ឋានបួ្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមកឃើញថា: កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ មានអំពើឃាតកម្ម ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ហ៊ឹង ហៅ [redacted] លីហ៊ឹង ភេទប្រុស អាយុ៣០ឆ្នាំ និងមានអំពើសមគំនិត ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ ជា យ៉ត និងឈ្មោះ [redacted] តុ។ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ត បានឆ្លើយបដិសេធថា ខ្លួនពុំបានប្រព្រឹត្តអំពើឃាតកម្ម និងពុំបានប្រព្រឹត្តអំពើសមគំនិត ជាមួយនឹងឈ្មោះ [redacted] ហ៊ឹង ហៅ [redacted] លីហ៊ឹង គឺពុំមានភស្តុតាងមកបញ្ជាក់បានទេ ចំពោះចម្លើយរបស់ជនជាប់ចោទ ដែលបានឆ្លើយកន្លងមកថា បានលឺ និងបានឃើញជនជាប់ចោទឈ្មោះ ហ៊ឹង វាយទៅលើជនរងគ្រោះ ហើយខ្លួនក៏នៅទីនោះ ចំណែកចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] តុ នៅពេលសវនាការថា ការឈ្លោះគ្នារវាងជនរងគ្រោះ និងជនជាប់ចោទឈ្មោះ [redacted] ហ៊ឹង ហៅ ហៀន លីហ៊ឹង និងឈ្មោះ [redacted] យ៉ត ពិតជាមាន ហើយនឹងមានអំពើវាយបណ្តាលឲ្យជនរងគ្រោះស្លាប់ ដែលមានឈ្មោះ [redacted] យ៉ត នៅនឹងកន្លែងកើតហេតុ រួចឈ្មោះ [redacted] តុ ក៏បានទូរស័ព្ទទៅប្រាប់ឈ្មោះ [redacted] ធុល ថា ឈ្មោះ [redacted] យ៉ត ហៅធី ឈ្លោះគ្នាជាមួយនឹងឈ្មោះ [redacted] ហ៊ឹង វាយជនរងគ្រោះបណ្តាលឲ្យស្លាប់ មានភស្តុតាងស៊ីសង្វាក់ទៅនឹងរបាយការណ៍ប៉ូលីស និងភស្តុតាងនៅសមត្ថកិច្ចចាប់យកនៅកន្លែងកើតហេតុ ដូច្នេះតំណាងអយ្យការយល់ឃើញថា មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ហ៊ឹង ហៅ [redacted] លីហ៊ឹង ភេទប្រុស អាយុ៣០ឆ្នាំ ពីបទ ឃាតកម្ម និងជនជាប់ចោទឈ្មោះ [redacted] យ៉ត ភេទប្រុស អាយុ៣៥ឆ្នាំ ពីបទ សមគំនិតក្នុងអំពើឃាតកម្ម ប្រព្រឹត្តនៅភូមិភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ១៩៩ និងមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ។ ចំពោះឈ្មោះ [redacted] តុ បានផ្តល់ចម្លើយសាក្សីជាពន្លឺដល់តុលាការ និងមានការដកពាក្យបណ្តឹងពីជនរងគ្រោះ ហេតុនេះតំណាងអយ្យការមិនធ្វើការប្តឹងសុំទេ។ តំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ២៩៧៦ អ.យ.វ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ ចំពោះជនជាប់ចោទឈ្មោះ [redacted] ហ៊ីង ហៅ [redacted] លីហ៊ីង និងឈ្មោះ [redacted] យ៉ត ទុកនៅដដែរ និងសុំឱ្យប្រធានក្រុមប្រឹក្សាផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] តុ បានធ្វើសេចក្តីសន្និដ្ឋានការពារថា: ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ, ក្រោយពីបានធ្វើការសិក្សាសំណុំរឿង និងក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ខ្លួនសុំឯកភាពតាមការសន្និដ្ឋានរបស់តំណាងអយ្យការដែលមិនបានប្តឹងសុំលើកូនក្តីខ្លួនឈ្មោះ [redacted] តុ។ ម្យ៉ាងកូនក្តីខ្លួនបានឆ្លើយរួចហើយថា នៅថ្ងៃកើតហេតុកូនក្តីខ្លួនស្រវឹង និងបានសំរាកក្នុងរោងការដ្ឋាន គ្រាន់តែបានដឹងលឺការឈ្លោះគ្នា លុះពេលក្រោកឡើងក៏បានឃើញឈ្មោះ [redacted] យ៉ត និងឈ្មោះ [redacted] ហ៊ីង ហៅ [redacted] លីហ៊ីង កាន់បំពង់ទីប នៅកន្លែងកើតហេតុ ចំណែកជនរងគ្រោះបានស្លាប់ហើយ។ រួចឈ្មោះ [redacted] ហ៊ីង ហៅ [redacted] លីហ៊ីង បានទាញដៃកូនក្តីខ្លួនរត់ តែកូនក្តីខ្លួនពុំបានរត់ទេ ថែមទាំងទៅរាយការណ៍ដល់មេការខ្លួនឈ្មោះ [redacted] ផុល មកជួយអន្តរាគមន៍ផងដែរ។ ចម្លើយនេះមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] ផុល , ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ត និងភស្តុតាងដែលមានក្នុងសំណុំរឿង ម្យ៉ាងវិញទៀតដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទូ ក៏បានធ្វើការដកពាក្យបណ្តឹងពីកូនក្តីខ្លួនផងដែរ ព្រោះគាត់ដឹងថា កូនក្តីខ្លួនមិនដែលមានទំនាស់អ្វីជាមួយជនរងគ្រោះ ហើយកូនក្តីខ្លួនមានចរិកស្លូតបូត ស្មោះត្រង់។ ដូច្នេះពុំមានភស្តុតាងណាមួយមកធ្វើការដាក់បន្ទុកលើកូនក្តីខ្លួន និងពុំមានភស្តុតាងណាមួយមកបញ្ជាក់ថា កូនក្តីខ្លួនមានចេតនាក្នុងការសមគំនិតក្នុងអំពើឃាតកម្មមកលើជនរងគ្រោះនោះទេ សំណូមពរសុំឱ្យប្រធានក្រុមប្រឹក្សាឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់តាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ, មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥០,៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយធ្វើការដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាពដូចធម្មតាវិញ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យ៉ត និងជនជាប់ចោទឈ្មោះ [redacted] ហ៊ីង ហៅ [redacted] លីហ៊ីង បានធ្វើសេចក្តីសន្និដ្ឋានការពារថា: ខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យ៉ត និងឈ្មោះ [redacted] ហ៊ីង ហៅ [redacted] លីហ៊ីង ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ២២៣២ ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៧ ខ្លួនសុំធ្វើសេចក្តីសន្និដ្ឋានដូចតទៅ: យោងតាមអង្គហេតុខាងលើ និងការពិភាក្សាដេញដោល សួរតទល់គ្នាក្នុងពេលសវនាការបានបង្ហាញឱ្យឃើញថា កូនក្តីខ្លួនពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ ព្រោះកូនក្តីខ្លួនបានឆ្លើយបដិសេធតាំងពីតំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌, តំណាក់កាលអយ្យការ, ចៅក្រមស៊ើបសួរ ក៏ដូចក្នុងពេលជំនុំជម្រះ ចំណុចដែលសំខាន់ៗរួមមាន: ១.ចម្លើយដ៏សំខាន់នោះ គឺចម្លើយរបស់ឈ្មោះ [redacted] ហ៊ីង ហៅ [redacted] លីហ៊ីង ថាតើនរណាជាជនដែលពិតប្រាកដ នរណាជាជនសមគំនិត, ២.ប្រសិនបើកូនក្តីខ្លួនឈ្មោះ [redacted] យ៉ត ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការមែន គាត់មិននៅកន្លែងការដ្ឋានសំណង់រួចធ្វើការជាធម្មតានោះទេ គាត់ប្រាកដជារត់ទៅក្រៅបាត់ហើយ មិនឱ្យសមត្ថកិច្ចធ្វើការឃាត់ខ្លួនដោយងាយៗនោះទេ, ៣.ចំពោះចំងាយដែលគាត់បានឆ្លើយជាចំងាយសមរម្យ ធម្មតាមនុស្សកាលបើផ្តោតអារម្មណ៍ទៅនឹងអ្វីមួយហើយ ប្រហែលជាអារម្មណ៍នោះមិនបានខ្វល់ពីសម្លេងខាងក្រៅ រឺសកម្មភាពនៅជុំវិញខ្លួនឡើយ, ៤.កូនក្តីខ្លួនបានឆ្លើយថា គាត់ពុំបានស្គាល់ជនរងគ្រោះ



Scanned with CamScanner

នោះទេ ហើយក៏មិនមានទំនាស់អ្វីជាមួយជនរងគ្រោះដែរ ព្រោះគាត់ទើបតែមកធ្វើការនៅការដ្ឋាននេះបានចំនួនតែ៥ថ្ងៃប៉ុណ្ណោះ មួយវិញទៀតសំដីរបស់ឈ្មោះ [redacted] តុ បានឆ្លើយថា លឺតែសម្លេងផូសៗដែលជាសម្លេងដំបង មិនមែនជាសម្លេងដុំឥដ្ឋនោះទេ មិនតែប៉ុណ្ណោះឈ្មោះ [redacted] តុ ក៏មិនបានឃើញកូនក្តីខ្លួនឈ្មោះ [redacted] យ៉ត កំពុងតែវាយទៅលើជនរងគ្រោះបណ្តាលឱ្យស្លាប់នោះទេ ហើយចំណុចដែលសំខាន់នោះ នៅក្នុងកោសលវិច័យឃើញ មានសំណល់ដុំឥដ្ឋ ដូច្នេះហើយនៅក្នុងថិរវេលាដែលពួកគាត់នាំគ្នារត់ចេញទៅក្រៅ ជាពេលដ៏សមល្មមដល់ជនទី៤ ក្នុងការប្រព្រឹត្តបទល្មើសបន្ថែមទៀត ព្រោះមិនដឹងថាគាត់មានទំនាស់ជាមួយអ្នកណាទៀតក្នុងការដ្ឋាននោះទេ សំណូមពរសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ សម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ និងដោះលែងកូនក្តីខ្លួនឈ្មោះ [redacted] យ៉ត ឱ្យមានសេរីភាពចាប់ពីពេលនេះតទៅ។ ចំណែកកូនក្តីខ្លួនឈ្មោះ [redacted] ហ៊ីង ហៅ [redacted] លីហ៊ីង មិនបានចូលខ្លួនមកឆ្លើយដោះបន្ទុកពីសកម្មភាព និងបទចោទប្រកាន់របស់តំណាងអយ្យការមកលើខ្លួននោះទេ ដោយធ្វើការរត់គេចខ្លួនបាត់តាំងពីថ្ងៃកើតហេតុមក ដូច្នេះសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាតាមច្បាប់ចុះ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] យ៉ត ហៅធី បាននិយាយសំដីចុងក្រោយបង្អស់ថា សុំឱ្យតុលាការដោះលែងខ្លួនឱ្យមានសេរីភាព និងលើកលែងចោទប្រកាន់ខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] តុ បាននិយាយសំដីចុងក្រោយបង្អស់ថា ឱ្យតុលាការដោះលែងខ្លួនឱ្យមានសេរីភាព និងលើកលែងចោទប្រកាន់ខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ស្ថិតនៅចំណុចភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពិតជាមានករណី ឃាតកម្ម និងសមគំនិតក្នុងអំពើឃាតកម្ម បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ហ៊ីង ([redacted] លីហ៊ីង) ហៅ ហ៊ីង ភេទប្រុស អាយុ៣០ឆ្នាំ ,ឈ្មោះ [redacted] យ៉ត ហៅធី ភេទប្រុស អាយុ៣២ឆ្នាំ ប្រាកដមែន។

២-កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ស្ថិតនៅចំណុចភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មិនមានករណី សមគំនិតក្នុងអំពើឃាតកម្ម បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] តុ ភេទប្រុស អាយុ២៧ឆ្នាំ នោះទេ។

៣-ជនជាប់ចោទឈ្មោះ [redacted] ហ៊ីង (ហៀន លីហ៊ីង) ហៅហ៊ីង ភេទប្រុស អាយុ៣០ឆ្នាំ និងឈ្មោះ [redacted] យ៉ត ហៅ ធី ភេទប្រុស អាយុ៣២ឆ្នាំ ជានីតិជន ជាកំណត់អាយុដែលអាចទទួលខុសត្រូវ ខាងព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនបាន ហើយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានការសង្ស័យ អំពីបញ្ហាស្មារតីឡើយ ដូច្នេះជននេះប្រាកដជាយល់ដឹងថា អំពើ



Scanned with CamScanner

របស់ខ្លួនពិតជាបានប៉ះពាល់ធ្ងន់ធ្ងរដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ។

៤-ជនជាប់ចោទឈ្មោះ [redacted] តុ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិជន មិនត្រូវបានទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ ហើយក៏ពុំមានសញ្ញាណណាមួយដែលនាំឱ្យមានការសង្ស័យទៅលើជននោះទេ ដូច្នេះអំពើរបស់ជននេះពិតជាមិនធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គមនោះឡើយ។

៥-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ត ហៅធី ថា: ខ្លួនមិនបានចូលរួមសមគំនិតក្នុងអំពើឃាតកម្ម ដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ ខ្លួនពិតជានៅនឹងកន្លែងកើតហេតុ និងបានឃើញ ជនរងគ្រោះនិយាយអ្វីជាមួយឈ្មោះ ហ៊ីង តែមិនដឹងនិយាយអ្វីនោះទេ ព្រោះរវល់តែនិយាយជាមួយប្រពន្ធរបស់ឈ្មោះហ៊ីង ស្រាប់តែពេលនោះខ្លួនលឺស្នូរសំលេងផ្ទុសៗ ក្រឡេកមើលទៅឃើញ ជនរងគ្រោះដួល ហើយឈ្មោះ ហ៊ីង បោះបំពង់ទឹបចោល ខ្លួនក៏បានរត់ចេញមកក្រៅ ហើយឈ្មោះ តុ ក៏រត់ចេញពីក្នុងមុង រួចនិយាយជាមួយឈ្មោះ ហ៊ីង តែខ្លួនមិនដឹងនិយាយពីអ្វីនោះទេ ពេលនោះឈ្មោះ តុ បានរត់ទៅផ្ទះមេការសំណង់ខ្លួនក៏ជិះម៉ូតូទៅផ្ទះវិញ។ ខ្លួនមិនដែលមានទំនាស់អ្វីជាមួយជនរងគ្រោះនោះទេ ព្រោះខ្លួនទើបតែមកធ្វើការនៅការដ្ឋាននេះបាន៥ថ្ងៃប៉ុណ្ណោះ។

៦-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] តុ ថា: កាលពីថ្ងៃទី ខែមិនចាំ ឆ្នាំ២០១៧ វេលាម៉ោង៥ និង០០នាទី ពួកខ្លួនមានគ្នាប្រហែល៨នាក់ មានរូបខ្លួន ,ឈ្មោះ ហ៊ីង ឈ្មោះ យ៉ត និងប្រាំនាក់ទៀតមិនស្គាល់ឈ្មោះ ពួកខ្លួនអង្គុយ ផឹកដល់ម៉ោង៦ល្ងាច អស់ស្រា៣លីត្រ ហើយក៏មិនបានឈ្លោះប្រហែកគ្នាដែរ រួចក៏បែកគ្នាទៅផ្ទះរៀងៗខ្លួន ចំណែកខ្លួនស្រវឹងពេកក៏ដេកលក់ក្នុងមុងនៅការដ្ឋានសំណង់ ដោយមិនដឹងថា នរណាមកកេះខ្លួនទេ ពេលដឹងខ្លួនឡើងទើបឃើញ មនុស្សដេកស្លាប់នៅក្បែរមុខរោងខ្លួនដេក ពេលនោះឈ្មោះ ហ៊ីង នៅទីនោះដែរ រួចឈ្មោះ ហ៊ីង បានបបួលខ្លួនរត់ តែខ្លួនពុំរត់ទៅជាមួយទេព្រោះខ្លួនពុំបានប្រព្រឹត្ត ពេលនោះឈ្មោះ ហ៊ីង ក៏បានរត់គេចបាត់តែម្តង។ ខ្លួនពុំបានសមគំនិត និងចូលរួមវាយសម្លាប់ទៅលើជនរងគ្រោះនោះទេ។ នៅថ្ងៃកើតហេតុនោះ ខ្លួនបានលឺសម្លេងឈ្លោះប្រកែកគ្នារវាងឈ្មោះហ៊ីង ឈ្មោះ យ៉ត និងជនរងគ្រោះអំពីរឿងស្រា ស្រាប់តែលឺសម្លេងផ្ទុសៗ ខ្លួនក៏ក្រោកមកឃើញជនរងគ្រោះដួលនៅកន្លែងកើតហេតុ និងបានឃើញឈ្មោះ ហ៊ីង កាន់ដំបងទឹបនឹងដៃ ចំណែកឈ្មោះ យ៉ត ក៏នៅទីនោះដែរ តែមិនឃើញមានកាន់អ្វីនោះទេ ខ្លួនក៏បានទូរស័ព្ទទៅប្រាប់ឈ្មោះ [redacted] ធុល ដែលជាមេការរបស់ការដ្ឋានថា មានគេវ៉ៃគ្នាបណ្តាលឲ្យជនរងគ្រោះស្លាប់ដោយឈ្មោះ [redacted] លីហ៊ីង និងឈ្មោះ [redacted] យ៉ត ជាអ្នកវាយ។ ខ្លួនបានរាយការណ៍ប្រាប់មេការរួចហើយ តែមិនបានប្តឹងសមត្ថកិច្ចនោះទេ ព្រោះខ្លួនទើបតែមកធ្វើការ ណាមួយមិនស្គាល់ផង ពេលសមត្ថកិច្ចឃាត់ខ្លួន ខ្លួនបានឆ្លើយប្រាប់ពីហេតុការណ៍ទាំងនោះអស់ហើយ ខ្លួនមិនដែលមានទំនាស់អ្វីជាមួយជនរងគ្រោះនោះទេ។

៧-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទូ ថា: ខ្លួនត្រូវជាប្រពន្ធរបស់ជនរងគ្រោះឈ្មោះ [redacted] ស៊ីវុធ ថារិន។ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ៦ និង០០ នាទីយប់ ខ្លួននិងប្តីបានទៅផ្ទះម្តាយ ហូបបាយជុំគ្នាដល់ម៉ោង៨យប់ ទើបត្រឡប់មកផ្ទះជួលវិញ ហើយគាត់បានដើរទៅការដ្ឋានសំណង់ដើម្បីសុំបារីគេជក់ រហូតដល់ម៉ោង១២យប់ មិនឃើញគាត់ត្រឡប់មកផ្ទះវិញ ខ្លួនក៏បានដើរទៅរកគាត់តែមិនឃើញ។ លុះមកដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ វេលាម៉ោង៦និង៣០នាទីព្រឹក ស្រាប់តែឃើញប្តីខ្លួនដេកស្លាប់នៅដីវាល។ ប្តីខ្លួនមិនដែលមានជំលោះ ជាមួយអ្នកណានោះទេ ហើយនៅថ្ងៃកើតហេតុខ្លួនមិនដឹងថាអ្នកណាវាយប្តីរបស់ខ្លួននោះដែរ។

៨-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ធុល ថា: កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង១៧ និង០០នាទី ខ្លួនដេកនៅកន្លែងរោងស្នាក់នៅ រហូតដល់ម៉ោង ១០យប់ ស្រាប់តែឈ្មោះ ធី (យ៉ត) ជាមេការខាងសំណង់បានទូរស័ព្ទមកខ្លួនឲ្យទៅមើលរោងកម្មករស្នាក់នៅរបស់គាត់ព្រោះមានអ្នកវាយគ្នា។ ពេលនោះខ្លួន និងឈ្មោះ ជា បាននាំ



Scanned with CamScanner

គ្នាទៅ ហើយបានឃើញឈ្មោះ តុ អង្គុយនៅក្នុងផ្ទះឈ្មោះ ធី រួចខ្លួនសួរឈ្មោះ តុ ថា មានរឿងអីបានជាឈ្មោះ ធី ទូរស័ព្ទហៅខ្លួនឱ្យមកឈ្មោះ តុ ប្រាប់ថា ឈ្មោះ ហ៊ីង និងប្រពន្ធរួមទាំងឈ្មោះ **ធី ហៅយ៉ត** បាននាំគ្នាវាយឈ្មោះ [redacted] ស៊ីវុធថាវិន ហៅស្នា ដេកស្តូកស្តឹងនៅមុខរោងកម្មករ មិនដឹងស្លាប់ រឺរស់នោះទេ។ បន្ទាប់មកខ្លួន, ឈ្មោះ តុ និងឈ្មោះ ជា បាននាំគ្នាដើរទៅមើល ឃើញឈ្មោះ ស្នា ដេកផ្អៀង មានឈាមហូរចេញពីក្បាល ខ្លួន និងឈ្មោះ តុ បានចាប់ជើងទាញ មើលទើបដឹងថាស្លាប់ ចំណែកឈ្មោះ ជា ឈរមើល រីឯប្រពន្ធរបស់ឈ្មោះ ធី (ឈ្មោះ ចាន់) ប្រាប់ឱ្យជួយសែងសាកសព ចេញពីមុខរោងកម្មករកុំឱ្យអ្នកដេកខ្លាច ខ្លួននិងឈ្មោះ តុ ក៏បានយកភួយក្រណាត់ដាក់សព និងសែងយកទៅទុកនៅចំងាយពីរោងប្រហែល១០ម៉ែត្រ រួចក៏នាំគ្នាទៅដេក។ លុះថ្ងៃទី០១ **ខែមេសា ឆ្នាំ២០១៧** ម៉ោង១០ព្រឹក សមត្ថកិច្ចបានហៅខ្លួនមកសាកសួរតែម្តង ខ្លួនមិនបានដឹងរឿងហេតុវាយគ្នានោះទេ ឈ្មោះ ហ៊ីង ជាកម្មករសំណង់ ចំណែកជនរងគ្រោះឈ្មោះ ស្នា ជាអ្នករកត្រី ស្នាក់នៅបណ្តោះអាសន្នក្បែរការដ្ឋានសំណង់។៩-ផ្អែកតាមការសួរដេញដោលនាពេលសវនាការ, អំណានចម្លើយសាក្សីឈ្មោះ [redacted] ធុល ព្រមទាំងភស្តុតាងមានលក្ខណៈស៊ីសង្វាក់នឹងគ្នា ដែលអាចបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ហ៊ីង ([redacted] លីហ៊ីង) ហៅហ៊ីង និងជនជាប់ ចោទឈ្មោះ [redacted] **យ៉ត ហៅ ធី** ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន។

៩-ជនជាប់ចោទឈ្មោះ [redacted] ហ៊ីង ([redacted] លីហ៊ីង) ហៅហ៊ីង ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ បានរត់គេចខ្លួនបាត់ក្រោយពីបានប្រព្រឹត្តបទល្មើសរួចហើយ ជនជាប់ចោទរូបនេះត្រូវបានចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួន **លេខ ៣៦០ (៩១) ដ.ច.ន ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧** គប្បីតុលាការពិចារណា។

១០-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ និងបានប្តឹងសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ**២៩៧៦ អ.យ.វ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧** ទុកនៅដដែរលើជនជាប់ចោទឈ្មោះ [redacted] ហ៊ីង ([redacted] លីហ៊ីង) ហៅហ៊ីង និងជនជាប់ ចោទឈ្មោះ [redacted] យ៉ត ហៅ ធី ប៉ុន្តែឈ្មោះ [redacted] តុ តំណាងអយ្យការមិនប្តឹងសុំទេ។

១១-អំពើប្រព្រឹត្តរបស់ឈ្មោះ [redacted] ហ៊ីង (ហៀន លីហ៊ីង) ហៅហ៊ីង ,និងឈ្មោះ [redacted] **យ៉ត ហៅធី** ជាអំពើមួយដែលបានដកហូត និងប៉ះពាល់ដល់អាយុជីវិតរបស់អ្នកដទៃ ហើយត្រូវបានច្បាប់បញ្ញត្តិក្នុងមាត្រា១៩៩ និងមាត្រា២៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

១២-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ចោទប្រកាន់ទៅលើឈ្មោះ [redacted] ហ៊ីង ([redacted] លីហ៊ីង)ហៅ ហ៊ីង ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ពីបទ ឃាតកម្ម និងឈ្មោះ [redacted] **យ៉ត ហៅធី** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ពីបទ សមគំនិតក្នុងអំពើឃាតកម្ម ប្រព្រឹត្តនៅភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ **ខែមីនា ឆ្នាំ២០១៧** បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ១៩៩ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

១៣-គ្មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ចោទប្រកាន់ទៅលើឈ្មោះ [redacted] តុ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ពីបទ សមគំនិតក្នុងអំពើឃាតកម្ម ប្រព្រឹត្តនៅភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ **ខែមីនា ឆ្នាំ២០១៧** បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ១៩៩ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

១៤-តាមពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី ៣១ **ខែឧសភា ឆ្នាំ២០១៧** ឃើញថាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទូ បានសុំដកពាក្យបណ្តឹងពីឈ្មោះ [redacted] តុ ភេទប្រុស អាយុ២៧ឆ្នាំ ដោយហេតុថា ខ្លួនមានការយល់ច្រលំ និងសុំឱ្យតុលាការមេត្តាលើកលែងចោទឈ្មោះ [redacted] តុ ឱ្យមានសេរីភាពវិញផង ប៉ុន្តែចំពោះឈ្មោះ [redacted] ហ៊ីង ([redacted] លីហ៊ីង) ហៅហ៊ីង និងឈ្មោះ [redacted] យ៉ត ដើមបណ្តឹងរដ្ឋប្បវេណីនៅតែប្តឹងទាមទារសំណងក្នុងម្នាក់ៗចំនួន ៥.០០០ (ប្រាំពាន់) ដុល្លាអាមេរិក និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទាំងពីរនោះទៅតាមច្បាប់។

១៥-វត្ថុចាប់យករួមមានៈ ដែកបំពង់ទីប ចំនួន០១ដើម ប្រវែង ០,៩១ Cm មុខកាត់ ៤Cm និងដុំឥដ្ឋប្រហោង ចំនួន ០១ដុំ តុលាការគប្បីរឹបអូសបំផ្លាញចោល។

**ហេតុដូច្នេះសម្រេច**

១-ឲ្យឈ្មោះ [redacted] តុ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ រួចផុតពីបទចោទប្រកាន់ ពីបទ សមគំនិតក្នុងអំពើឃាតកម្ម ប្រព្រឹត្តនៅភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ១៩៩ និងមាត្រា ២៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

២-ផ្តន្ទាទោសលើ

ក-ឈ្មោះ [redacted] ហ៊ឹង ([redacted] លីហ៊ឹង) ហៅហ៊ឹង ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១៤ (ដប់បួន) ឆ្នាំ ពីបទ ឃាតកម្ម ប្រព្រឹត្តនៅភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ១៩៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ខ-ឈ្មោះ [redacted] យ៉ត ហៅធី ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ១៤ (ដប់បួន) ឆ្នាំ ពីបទ សមគំនិតក្នុងអំពើឃាតកម្ម ប្រព្រឹត្តនៅភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ១៩៩ និងមាត្រា ២៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៣-បង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនឈ្មោះ [redacted] ហ៊ឹង ([redacted] លីហ៊ឹង) ហៅ ហ៊ឹង ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មកផ្តន្ទាទោសតាមអំណាចសាលក្រមនេះ ទៅពន្ធនាគារព្រៃស(ម១) នៃក្រសួងមហាផ្ទៃតាមបញ្ញត្តិមាត្រា ៣៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៤-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ឹង ([redacted] លីហ៊ឹង) ហៅ ហ៊ឹង និងឈ្មោះ [redacted] យ៉ត ហៅ ធី រួមគ្នាសងសំណងជម្ងឺចិត្តចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នូ ។

៥-វត្ថុចាប់យករួមមានៈ ដែកបំពង់ទីប ចំនួន០១ដើម ប្រវែង ០,៩១ Cm មុខកាត់ ៤Cm និងដុំឥដ្ឋប្រហោងចំនួន ០១ដុំ ត្រូវរឹបអូសបំផ្លាញចោល។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] យ៉ត ,ជនជាប់ចោទឈ្មោះ [redacted] តុ, មេធាវីការពារជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នូ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហ៊ឹង ([redacted] លីហ៊ឹង) ហៅ ហ៊ឹង និងប្រកាសជាសាធារណៈនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨។

-គូភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

.............................................................................................................

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

" បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ពស ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨

**ក្រឡាបញ្ជី**

[redacted]